ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី

លេខៈ ៩១ សលរ.ច.៣១៩

# សារលិខិតជូនពរ

# សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

# ប្រធានព្រឹទ្ធសភា និងជាប្រធានក្រុមឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ

# នៃព្រះរាជាណាចក្រកម្ពុជា

# នៅក្នុងឱកាសពិធីចម្រើនជន្មាយុគម្រប់៧២ឆ្នាំ ឈានចូល៧៣ឆ្នាំ

## សម្តេចអគ្គមហាសេនាបតីតេជោប្រធានព្រឹទ្ធសភា ជាទីគោរពដ៏ខ្ពង់ខ្ពស់

នៅក្នុងឱកាសដ៏នក្ខត្តឫក្សវិសេសវិសាលប្រពៃថ្លៃថ្លានៃពិធីចម្រើនជន្មាយុគម្រប់៧២ឆ្នាំ ឈានចូល៧៣ឆ្នាំ របស់ សម្តេចអគ្គមហាសេនាបតីតេជោប្រធានព្រឹទ្ធសភា ដែលនឹងប្រព្រឹត្តទៅនាថ្ងៃចន្ទ ១កើត ខែស្រាពណ៍ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី៥ ខែសីហា ឆ្នាំ២០២៤ ខាងមុខនេះ តាងនាមថ្នាក់ដឹកនាំនិងមន្ត្រីរាជការនៃទីស្តីការគណៈរដ្ឋមន្ត្រី និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ ព្រមទាំងភរិយា ខ្ញុំសូមធ្វើអភិវន្ទនកិច្ចសម្តែងនូវសេចក្តីអំណរសាទរឥតឧបមា និងសូមចូលរួមជូននូវសព្ទសាធុការពរជ័យ សិរីសួស្តី ជ័យមង្គល វិបុលសុខ បវរមហាប្រសើរគ្រប់ប្រការ គោរពជូនចំពោះ **សម្តេចតេជោប្រធានព្រឹទ្ធសភា** សូមសមប្រកបដោយបញ្ញាញាណភ្លឺថ្លាត្រចះត្រចង់ កាយពលរឹងមាំខ្លាំងក្លា សុខភាពល្អបរិបូរណ៍ ជន្មាយុយឺនយូរ ដើម្បីដឹកនាំព្រឹទ្ធសភា ដែលជាស្ថាប័ននីតិប្បញ្ញត្តិកំពូលនៃព្រះរាជាណាចក្រកម្ពុជា ឱ្យសម្រេចបាននូវស្នាដៃថ្មីៗធំធេងបន្ថែមទៀតក្នុងការចូលរួមដំណើរការពង្រឹងនីតិរដ្ឋ លទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស ការគោរពសិទ្ធិមនុស្ស ការពង្រឹងសមត្ថភាពស្ថាប័ន និងការកសាងសមិទ្ធផលសង្គមជាច្រើន ដើម្បីវឌ្ឍនភាពសង្គមកាន់តែមានការរីកចម្រើនរុងរឿងខ្លាំងក្លា សំដៅលើកកម្ពស់កិត្យានុភាពជាតិ សុខុមាលភាព និងជីវភាពរបស់ប្រជាពលរដ្ឋឱ្យកាន់តែល្អប្រសើរថែមទៀត។

យើងខ្ញុំទាំងអស់គ្នា សូមសម្តែងនូវការដឹងគុណយ៉ាងជ្រាលជ្រៅបំផុតប្រកបដោយកតញ្ញូតាធម៌និងកតវេទិតាធម៌យ៉ាងស្មោះស្ម័គ្របំផុតចំពោះ **សម្តេចតេជោប្រធានព្រឹទ្ធសភា** ដែលកាលនៅជាប្រមុខរាជរដ្ឋាភិបាល បានខិតខំប្រឹងប្រែងអស់ពីកម្លាំងកាយចិត្ត ប្រាជ្ញាស្មារតី និងបទពិសោធប្រកបដោយគតិបណ្ឌិតដ៏មហាស្ចារ្យ ក្នុងការដឹកនាំកម្ពុជាទទួលបាននូវសុខសន្តិភាពពេញលេញលើផ្ទៃប្រទេស ឯកភាពជាតិ បូរណភាពទឹកដី ស្ថិរភាពនយោបាយ សន្តិសុខសង្គម និងសណ្តាប់ធ្នាប់សាធារណៈ ដែលជាបុព្វបទដ៏សំខាន់ក្នុងការអភិវឌ្ឍនិងការកែទម្រង់ស៊ីជម្រៅលើគ្រប់វិស័យប្រកបដោយភាពស៊ីចង្វាក់គ្នា ដែលមានអភិបាលកិច្ចល្អជាស្នូលដ៏រឹងមាំ ដើម្បីកំណើន ការងារ សមធម៌ ប្រសិទ្ធភាព និងចីរភាព សំដៅលើកកម្ពស់កិត្យានុភាពជាតិ ថែរក្សាសុខសន្តិភាពឱ្យបានស្ថិតស្ថេរគង់វង្ស លើកកម្ពស់សុខុមាលភាព និងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ។ ជាមួយគ្នានេះ **សម្តេចតេជោ** បានបន្សល់ជូនថ្នាក់ដឹកនាំជំនាន់ក្រោយ នូវស្នាដៃដែលជាគំរូវីរភាពសំខាន់ៗ រួមមាន ការប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ ការស្វែងរកនិងការចាក់វ៉ាក់សាំងជូនប្រជាជននៅទូទាំងប្រទេស ការបន្សាំ Pls

ប្រជាជនជាមួយនឹងការរស់នៅក្នុងគន្លងប្រក្រតីភាពថ្មី ការបញ្ចៀសបាននូវហានិភ័យសង្គមដែលបង្កឡើងដោយវិបត្តិជំងឺកូវីដ-១៩ ការប្រកាសបើកប្រទេស បើកសេដ្ឋកិច្ចសង្គម និងបើកវិស័យទេសចរណ៍ឡើងវិញ ការធ្វើជាម្ចាស់ផ្ទះក្នុងកិច្ចប្រជុំកំពូលអាស៊ី-អឺរ៉ុបលើកទី១៣ និងការរក្សាបានស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ព្រមទាំងការដឹកនាំនិងអំពាវនាវដល់ជនរួមជាតិយើងទាំងក្នុងនិងក្រៅប្រទេសឱ្យចូលរួមចំណែកក្នុងយុទ្ធនាការបំផ្លាញចោលគ្រាប់មីននិងគ្រាប់មិនទាន់ផ្ទុះឈានទៅបញ្ចប់សោកនាដកម្មលើទឹកដីដ៏កម្សត់របស់យើង នៅត្រឹមឆ្នាំ២០២៥ និងជួយប្រជាជនដែលជួបប្រទះនូវឧបទ្ទវហេតុគ្រោះមហន្តរាយនានា។ ជាពិសេស ការធ្វើជាប្រធានអាស៊ានប្តូរវេនក្នុងឆ្នាំ២០២២ ប្រកបដោយបទពិសោធចាស់ទុំ និងទេពកោសល្យខ្ពស់ក្នុងការដឹកនាំកិច្ចប្រជុំកំពូលអាស៊ានលើកទី៤០និងលើកទី៤១ និងកិច្ចប្រជុំកំពូលពាក់ព័ន្ធដែលធ្វើឡើងដោយផ្ទាល់នៅកម្ពុជា បានដំណើរការទៅយ៉ាងរលូនទទួលបានលទ្ធផលផ្លែផ្កាជាប្រវត្តិសាស្ត្រ។ ការរៀបចំព្រឹត្តិការណ៍កីឡាស៊ីហ្គេមលើកទី៣២ និងអាស៊ានប៉ារ៉ាហ្គេមលើកទី១២ ឆ្នាំ២០២៣ បានបិទបញ្ចប់ប្រកបដោយជោគជ័យយ៉ាងធំធេង។ ជាងនេះទៀត **សម្តេចតេជោប្រធានព្រឹទ្ធសភា** បានផ្តួចផ្តើមបង្កើតគម្រោងព្រែកជីកហ្វូណនតេជោជាព្រែកជីកប្រវត្តិសាស្ត្រលើកទី១ នៅកម្ពុជា ដែលនឹងផ្តល់អត្ថប្រយោជន៍ដ៏មហាសាលដល់ប្រទេសកម្ពុជា ជាពិសេស មានឯករាជ្យភាពខាងផ្លូវដឹកជញ្ជូនពីទន្លេទៅកាន់សមុទ្រ និងពីសមុទ្រមកកាន់ទន្លេ ទាំងនេះសុទ្ធតែជាសមិទ្ធផលដ៏ធំធេង ដែលកើតចេញពីការដឹកនាំប្រកបដោយគតិបណ្ឌិតនិងជាទីមោទនៈបំផុតរបស់ **សម្តេចតេជោប្រធានព្រឹទ្ធសភា**។

ឆ្លៀតក្នុងឱកាសដ៏មហាមង្គលាភិរម្យប្រសើរថ្លៃថ្លានៃពិធីចម្រើនជន្មាយុដ៏ឧត្តុង្គឧត្តមនេះផងដែរ យើងខ្ញុំទាំងអស់គ្នាសូមលើកហត្ថបួងសួងដល់វត្ថុស័ក្តិសិទ្ធិទាំងឡាយក្នុងលោក គុណបុណ្យព្រះរតនត្រ័យ គុណកែវទាំងបី ឫទ្ធិបារមីថែរក្សាប្រាង្គប្រាសាទអង្គរ ជាពិសេស ទេវតាថែរក្សា **ឆ្នាំរោង** ឆស័ក ព្រះនាម **មហោទរាទេវី** សូមតាមជួយថែរក្សាការពារ អភិបាល ប្រោះព្រំនូវសព្ទសាធុការពរជ័យគ្រប់ប្រការជូនចំពោះ **សម្តេចតេជោប្រធានព្រឹទ្ធសភា** និង**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** ព្រមទាំងក្រុមគ្រួសារជាទីស្រឡាញ់ សូមសមប្រកបដោយពុទ្ធពរដ៏ឧត្តុង្គឧត្តមថ្លៃថ្លាទាំងប្រាំប្រការគឺ **អាយុ វណ្ណៈ សុខៈ ពលៈ និងបដិភាណៈ** ជានិច្ចនិរន្តរ៍ កុំបីឃ្លៀងឃ្លាតឡើយ។

សូមសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភា និងជាប្រធានក្រុមឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា មេត្តាទទួលនូវគារវកិច្ចដ៏ស្មោះស្ម័គ្របំផុតពីខ្ញុំនិងភរិយា។ ៕

ថ្ងៃ ពុធ ៤ រោច ខែ អាសាឍ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែកក្កដា ឆ្នាំ២០២៤

**តំណាងថ្នាក់ដឹកនាំនិងមន្ត្រីរាជការនៃទីស្តីការគណៈរដ្ឋមន្ត្រី**

**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**

**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**វង្សី វិស្សុត**